ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

លេខ : ០៦៧ គ.ឃ.ស

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០...

សេចក្ដីណែនាំ

ដើម្បីអនុវត្តសេចក្ដីសំរេចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ លេខ ០៦៦ គ.ឃ.ស ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២

អនុលោមមាត្រា ៦២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំ ទី មួយនៃអាណត្តិរបស់ខ្លួន ។

យោងតាមសេចក្ដីសម្រេចលេខ ០៦៦ គ.ឃ.ស. ចុះថ្ងៃ ទី ២៦ ខែ សីហា ឆ្នាំ ២០០២ របស់គណៈ-កម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ស្ដីពីការបង្កើតប្រព័ន្ធគាំទ្រដល់ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងខេត្ត ក្រុងចំនួន៧ គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងកែប ខេត្តកណ្ដាល ខេត្តកោះកុង ខេត្តស្ទឹងត្រែង និង ខេត្តមណ្ឌលគិរី ។

ដោយពិនិត្យឃើញពីតម្រូវការពិសេសផ្នែកហិរញ្ញវត្ថុ និង ផ្នែកបច្ចេកទេសរបស់ខេត្តចំនួនបួន គឺខេត្ត កណ្ដាល ខេត្តកោះកុង ខេត្តមណ្ឌលគិរី និង ខេត្តស្ទឹងត្រែង និង ក្រុងចំនួនបី គឺ ក្រុងភ្នំពេញ ក្រុងព្រះសីហនុ និង ក្រុងកែប ដើម្បីគាំទ្រដល់ឃុំ សង្កាត់ក្នុងការកសាងផែនការអភិវឌ្ឍន៍រយៈពេលវែងរបស់ខ្លួន ។

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់សូមធ្វើការណែនាំដល់គ្រប់អភិបាលខេត្ត ក្រុងទាំង៧ ដូចបានរៀបរាប់ខាងលើដើម្បីរៀបចំគំរោង និង កម្មវិធីគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងខេត្ត ក្រុងរបស់ខ្លួនដូចតទៅ :

I.ឈ្មោះគំរោង

គ្រប់ខេត្ត ក្រុង នីមួយៗត្រូវរៀបចំគំរោងគាំទ្រដល់ដំណើរការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងរយៈពេលអន្តរកាលដោយមានឈ្មោះថា គំរោងគាំទ្រការកសាងផែនការឃុំ សង្កាត់ Project Support to Commune/Sangkat Planing (PSCP) ។

II.ការរៀបចំគណៈកម្មាធិការគ្រប់គ្រងគំរោង

ក្នុងដំណើរការអនុវត្តគំរោងនេះត្រូវរៀបចំឱ្យមាន " គណៈកម្មាធិការគ្រប់គ្រងគំរោង " PROJECT MANAGEMENT COMMITTEE (PMC) និង ក្រុមគាំទ្រ SUPPORT TEAM ។

ក. សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងគំរោងមាន :

- អភិបាលខេត្ត ក្រុង ជា ប្រធាន
- អភិបាលរងទី មួយខេត្ត ក្រុង ជា អនុប្រធានទីមួយ
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ជា អនុប្រធានទីពីរ
- ប្រធានមន្ទីរផែនការខេត្ត ក្រុង ជា សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត ក្រុង ជា សមាជិក
- ប្រធានមន្ទីរកិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក
- មន្ត្រីបង្គោលអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ជា លេខាធិការ

ប្រធានគណៈកម្មាធិការគ្រប់គ្រងគំរោងអាចអញ្ជើញប្រធាន ឬ មន្ត្រីនៃមន្ទីរនានានៅជុំវិញខេត្ត ក្រុង ទីភ្នាក់ងារអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ឱ្យចូលរួមប្រជុំនៅពេលចាំបាច់ ។ អ្នកដែលត្រូវបានអញ្ជើញចូលរួមប្រជុំនេះ ត្រូវផ្តល់ពត៌មានទាំងឡាយដែលគណៈកម្មាធិការគ្រប់គ្រងគំរោងមានសំណូមពរ និងមានសិទ្ធិក្នុងការផ្តល់យោបល់ដល់គណៈកម្មាធិការគ្រប់គ្រងគំរោង តែពុំមានសិទ្ធិក្នុងការអនុម័តទេ ។ អង្គភាពរដ្ឋបាលមូលដ្ឋាន គឺជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការគ្រប់គ្រងគំរោង ។

ខ. ក្រុមគាំទ្រ

ក្រុមគាំទ្រ អាចមានប្រធានក្រុម និង សមាជិកក្រុម គឺជាក្រុមនៃមន្ត្រីរាជការ ឬ ជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល/សង្គមស៊ីវិល ដែលមានជំនាញផ្នែកបណ្តុះបណ្តាល ការសំរបសំរួល ក្នុងកិច្ចអភិវឌ្ឍន៍ជនបទ និង ដំណើរការកសាងផែនការ ប៉ុន្តែកំរិតជំនាញរបស់មន្ត្រីទាំងនេះ ត្រូវស្របទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ហើយទទួលខុសត្រូវចំពោះគណៈកម្មាធិការគ្រប់គ្រងគំរោងក្នុងការអនុវត្តន៍គំរោង ។

ក្រុមគាំទ្រ ត្រូវចែកចេញជាពីរកំរិត គឺក្រុមគាំទ្រនៅថ្នាក់ខេត្ត ក្រុង និង ក្រុមគាំទ្រនៅថ្នាក់ ស្រុក ខណ្ឌ (Provincial Support Team(PST) និង District Support Team(DST) ។

III. តួនាទី ភារកិច្ច និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគំរោង

គណៈកម្មាធិការគ្រប់គ្រងគំរោងមានតួនាទី និង ភារកិច្ចដូចខាងក្រោម :

ក. តួនាទីរួម :

- រៀបចំវិធីសាស្ត្រយុទ្ធសាស្ត្រ និង ផែនការការងារទាំងអស់ ដើម្បីជួយដល់ដំណើរការកសាង ផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ នៅក្នុងដំណាក់កាលអន្តរកាល ពីខែកញ្ញា ឆ្នាំ ២០០២ ដល់ ខែ មករា ឆ្នាំ ២០០៣ ។
- ធានាអោយបានថាឃុំ សង្កាត់ទាំងអស់ទទួលបានការគាំទ្រចាំបាច់ពីមន្ទីរនានាជុំវិញខេត្ត ក្រុងអភិបាលស្រុក ខណ្ឌ ការិយាល័យផ្សេងៗ នៅស្រុក ខណ្ឌ និង នៅមូលដ្ឋាន ។
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត ក្រុង ។

- ជួយអភិបាលខេត្ត ក្រុង ក្នុងការពិនិត្យនិត្យានុកូលភាពលើសេចក្តីព្រាងផែនការឃុំ សង្កាត់ ហើយលើកអនុសាសន៍ជូនអភិបាលខេត្ត ក្រុង ដើម្បីផ្តល់មតិលើសេចក្តីព្រាងផែនការនេះ ។

ខ. ការសំរបសំរួល

- ផ្អែកលើប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងត្រូវធ្វើការសំរបសំរួលតាមរយៈការប្រជុំ ការប្រាស្រ័យទាក់ទង និង ការប្រគល់ភារកិច្ចដល់ស្ថាប័នដែលពាក់ព័ន្ធក្នុងខេត្ត ក្រុង ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំកសាងផែនការរបស់ខ្លួនបាន ។

- គណៈកម្មាធិការគ្រប់គ្រងគំរោង ត្រូវសហការ យ៉ាងជិតស្និទ្ធជាមួយមន្ទីរនានាជុំវិញខេត្ត ក្រុងដើម្បីរួមចំណែកទាំងធនធានសម្ភារៈ និង ធនធានមនុស្សក្នុងការគាំទ្រដល់ឃុំ សង្កាត់មានលទ្ធភាពដំណើរការកសាងផែនការអភិវឌ្ឍន៍របស់ខ្លួន ។

- សំរបសំរួល និង ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬ សង្គមស៊ីវិលនៅក្នុងខេត្ត ក្រុង ដើម្បី គាំទ្រដល់ដំណើរការនេះ ដូចជា ធនធានបច្ចេកទេស ធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុ ។

- ណែនាំស្រុក ខណ្ឌ និង ឃុំ សង្កាត់ ដើម្បីអនុវត្តដំណើរការ ។

- រៀបចំសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ជាមួយមន្ទីរជំនាញនៅជុំវិញខេត្ត ក្រុង ការិយាល័យ នៅស្រុក ខណ្ឌ ឃុំ សង្កាត់ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ទីភ្នាក់ងារអភិវឌ្ឍន៍ ។ល ។

- ផ្អែកតាមជំនាញរបស់ខ្លួន មន្ទីរខេត្ត ក្រុងដែលជាសមាជិករបស់គណៈកម្មាធិការគ្រប់គ្រងគំរោង ត្រូវផ្តល់ការគាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទាំងមូល ពិសេសការបញ្ជូនបុគ្គលិកដែល មានសមត្ថភាព អោយទៅបំពេញការងារជាអ្នកសំរបសំរួលតាមការចាំបាច់ ។

- មន្ទីរនានាជុំវិញខេត្ត ក្រុង ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់គណៈកម្មាធិការគ្រប់គ្រងគំរោង និង ក្រុមប្រឹក្សាឃុំ សង្កាត់តាមសំណូមពរចាំបាច់ ។

- មន្ទីរទាំងអស់ជុំវិញខេត្ត ក្រុង និង ការិយាល័យនៅតាមស្រុក ខណ្ឌ ត្រូវចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ខណ្ឌ ចូលរួមនៅក្នុងដំណើរការកសាងផែនការ (នៅពេលចាំបាច់) ហើយត្រូវផ្តល់ពត៌មានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង បញ្ជាក់ពីសកម្មភាពថវិកា និង អាទិភាពដែលត្រូវដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ។

- មន្ទីរផែនការខេត្ត ក្រុង ត្រូវផ្តល់ពត៌មាន/ទិន្នន័យចាំបាច់ទាំងអស់សំរាប់កសាងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ និងបញ្ជូនបុគ្គលិកអោយបំពេញការងារជាអ្នកសំរបសំរួលនៅពេលត្រូវការចាំបាច់ ។

- មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ពិនិត្យលទ្ធភាពដើម្បីផ្តល់បុគ្គលិកបច្ចេកទេសរបស់ខ្លួន ឱ្យជួយគាំទ្រដំណើរការកសាងផែនការ ។

- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានតួនាទីផ្តល់ការណែនាំដល់ក្រុមគាំទ្រអំពីបច្ចេកទេស នៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ផ្តល់ថវិកា និង វិភាជន៍ធនធានដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

- មន្ទីរកិច្ចការនារី និង អតីតយុទ្ធជនមានតួនាទីផ្តល់ការគាំទ្រអោយមានការអនុវត្តន៍នយោបាយបញ្ជ្រាបយេនឌ័រក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

គ. ការជ្រើសរើស និង គ្រប់គ្រងក្រុមគាំទ្រ

គណៈកម្មាធិការគ្រប់គ្រងគំរោងត្រូវចាត់ចែង រៀបចំជ្រើសរើស គ្រប់គ្រង ពិនិត្យ និង តាមដានអ្នកគាំទ្រ ហើយធានាអោយអ្នកគាំទ្រដែលបានជ្រើសរើសឡើង អាចបំពេញការងារបានទៀងទាត់ និង មានគុណភាព ។ កិច្ចការលំអិតអាចរួមមាន :

១. ការរៀបចំបង្កើតគណៈកម្មការជ្រើសរើស អ្នកគាំទ្រ

គណៈកម្មាធិការគ្រប់គ្រងគំរោងត្រូវបង្កើតគណៈកម្មការជ្រើសរើសដែលមានសមាជិក ~~៥~~ ៧ រូបរួមមាន:

- អភិបាលខេត្ត ក្រុង ជាប្រធាន
- អភិបាលរងទីមួយខេត្ត ក្រុង ជាអនុប្រធាន
- ប្រធានមន្ទីរផែនការ ជាសមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ជាសមាជិក
- ប្រធានមន្ទីរកិច្ចការនារី និង អតីតយុទ្ធជន ជាសមាជិក
- តំណាងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ជាសមាជិក
- មន្ត្រីបង្គោលអង្គភាព រដ្ឋបាលមូលដ្ឋាន ជាលេខាធិការ ។

២. ដំណើរការជ្រើសរើសអ្នកគាំទ្រ

ក្នុងដំណើរការជ្រើសរើសអ្នកគាំទ្រ គណៈកម្មការជ្រើសរើសត្រូវ :

- ផ្សព្វផ្សាយជាសាធារណៈនូវពត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងការជ្រើសរើសអ្នកគាំទ្រ :
  - ° ការបញ្ជាក់ពីល័ក្ខខ័ណ្ឌការងាររបស់អ្នកគាំទ្រ
  - ° បញ្ជាក់លំអិតពីលក្ខណៈសម្បត្តិរបស់បេក្ខជន
  - ° រយៈពេល និង កម្រៃនៃការបំពេញភារកិច្ច
  - ° ល័ក្ខខ័ណ្ឌនៃការជ្រើសរើស...
- កំណត់កាលបរិច្ឆេទនៃការជ្រើសរើស

- ត្រួតពិនិត្យបញ្ជីបេក្ខជន និង ដំណើរការជ្រើសរើសជាបឋម
- ដឹកនាំការធ្វើសម្ភាសន៍ ត្រួតពិនិត្យការធ្វើវិញ្ញាសាសរសេរ និង ដាក់ពិន្ទុ(ដំណើរការសម្ភាសន៍ និង ការធ្វើវិញ្ញាសាសរសេរត្រូវធ្វើដោយសម្ងាត់)
- បេក្ខជនដែលជាប់ជាស្ថាពរ នឹងត្រូវផ្តល់ការងារជូន

លក្ខណៈវិនិច្ឆ័យនៃអ្នកគាំទ្រ :

អ្នកគាំទ្រ ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- មានវិញ្ញាបនបត្រទុតិយភូមិ (Bacc II) អ្នកមានបរិញ្ញាប័ត្រ នឹងត្រូវផ្តល់អាទិភាព
- មានបទពិសោធន៍ការងារយ៉ាងតិចបីឆ្នាំក្នុងមុខងារជាមន្ត្រីនៃរាជរដ្ឋាភិបាល ឬ ជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ និង អង្គការមិនមែនរដ្ឋាភិបាល ឬ សង្គមស៊ីវិលផ្សេងៗ ។

សំគាល់ : *គ្រូឧទ្ទេសដែលបានទទួលការបណ្តុះបណ្តាលក្រោមគំរោងគាំទ្រវិមជ្ឈការ នឹងត្រូវផ្តល់អាទិភាពនៅក្នុងការជ្រើសរើស ។ អ្នកគាំទ្រថ្មីនឹងត្រូវជ្រើសរើសប្រសិនបើមានតំរូវការដោយមានមូលហេតុច្បាស់លាស់ ។ ប្រសិនបើចំនួនអ្នកគាំទ្រដែលមានស្រាប់ មានចំនួនគ្រប់គ្រាន់តាមគំរោងហើយនោះ នឹងគ្មានការជ្រើសរើសអ្នកគាំទ្រថ្មីបន្ថែមទេ ។ ក្នុងករណីអ្នកគាំទ្រជាបុគ្គលិកនៃអង្គការមិនមែនរដ្ឋាភិបាល និង សង្គមស៊ីវិល នឹងត្រូវទទួលប្រាក់ឧបត្ថម្ភពីស្ថាប័នរបស់ខ្លួន ហើយអ្នកគាំទ្រទាំងនេះត្រូវបំពេញការងារជាក្រុម និងអនុវត្តតាមវិធីសាស្ត្រនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដែលបានកំណត់ ។*

(មានការណែនាំលំអិតក្នុងឧបសម្ព័ន្ធទី១)

ឃ. ការគ្រប់គ្រង និង ការត្រួតពិនិត្យអ្នកគាំទ្រ

- គណៈកម្មាធិការគ្រប់គ្រងគំរោងត្រូវគ្រប់គ្រងអ្នកគាំទ្រ ។
- អ្នកគាំទ្រត្រូវទទួលខុសត្រូវចំពោះមុខគណៈកម្មាធិការគ្រប់គ្រងគំរោង ក្នុងការអនុវត្តនីភារកិច្ចតាមល័ក្ខខ័ណ្ឌការងារដែលបានកំណត់ ។
- អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដែលជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងគំរោង ត្រូវរក្សាពតិមានរបស់អ្នកគាំទ្រ ចាត់តាំង និង ប្រគល់ភារកិច្ចអ្នកគាំទ្រ ឱ្យបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង ត្រួតពិនិត្យតាមដានរាល់សកម្មភាពការងាររបស់អ្នកគាំទ្រ ។
- គណៈកម្មាធិការគ្រប់គ្រងគំរោងអាចបញ្ឈប់អ្នកគាំទ្រ ក្នុងករណីអ្នកគាំទ្រមិនបំពេញបានតាមល័ក្ខខ័ណ្ឌការងាររបស់ខ្លួន ។
- គណៈកម្មាធិការគ្រប់គ្រងគំរោងតាមរយៈអភិបាលខេត្ត ក្រុង អាចធ្វើប្រតិភូកម្មភារកិច្ចក្នុងការគ្រប់គ្រង និង ការត្រួតពិនិត្យអ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌដល់អភិបាលស្រុក ខណ្ឌ ។

• អ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌ ត្រូវមានទីស្នាក់ការធ្វើការងារនៅក្នុងសាលាស្រុក ខណ្ឌ ។

ង. ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់អ្នកគាំទ្រ : អ្នកគាំទ្រនឹងទទួលប្រាក់ឧបត្ថម្ភ និង ផលប្រយោជន៍ដោយផ្អែកទៅលើគោលនយោបាយរបស់កម្មវិធី ប្រាក់ឧបត្ថម្ភនេះចាត់ទុកជាប្រាក់បន្ថែមលើបៀវត្សរ៍ សម្រាប់មន្ត្រីនៃរាជរដ្ឋាភិបាល ។

IV. តួនាទី ភារកិច្ចរបស់អភិបាលស្រុក ខណ្ឌ :

ផ្អែកតាមប្រកាសស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អភិបាលខេត្ត ក្រុងអាចធ្វើប្រតិភូកម្មអំណាចដល់អភិបាលស្រុក ខណ្ឌ ដើម្បីត្រួតពិនិត្យ និង តាមដានអ្នកគាំទ្រដែលបំពេញការងារក្នុងស្រុក ខណ្ឌ ។

អភិបាលស្រុក ខណ្ឌត្រូវ :

• ធានាអោយបានថាអ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌបំពេញការងារបានត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌការងាររបស់ខ្លួន ។

• ធ្វើសេចក្តីរាយការណ៍ទៀងទាត់ស្តីពីការវិវឌ្ឍន៍ ក្នុងការអនុវត្តន៍កិច្ចការនេះជូនអភិបាលខេត្ត ក្រុង។

• ធ្វើសំណូមពរ និងផ្តល់អនុសាសន៍ជូនអភិបាលខេត្ត ក្រុងពីរបៀបដោះស្រាយបញ្ហា និងការកែលំអក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តន៍ការងាររបស់អ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌ។

• សម្របសម្រួលជាមួយការិយាល័យនានានៅស្រុក ខណ្ឌ អោយជួយគាំទ្រនៅក្នុងដំណើរការកសាងផែនការឃុំ សង្កាត់ ។

• ធ្វើទំនាក់ទំនងជាមួយបណ្តាការិយាល័យនៅស្រុក ខណ្ឌ និង អង្គការមិនមែនរដ្ឋាភិបាលអោយផ្តល់ពត៌មាន និង ចូលរួមផ្តល់នូវជំនួយបច្ចេកទេសចាំបាច់ដល់អ្នកគាំទ្រនៅថ្នាក់ស្រុក ខណ្ឌ និង ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដំណើរការកសាងផែនការ ។

• លើកសំណើជូនគណៈកម្មាធិការគ្រប់គ្រងគំរោង តាមរយៈអ្នកគាំទ្រខេត្ត ក្រុង ដើម្បីរៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ខណ្ឌ។

• ណែនាំអ្នកសំរបសំរួលថ្នាក់ស្រុក ខណ្ឌ ពីទិដ្ឋភាពនិត្យានុកូលភាពនៃការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

V. តួនាទី និង ការទទួលខុសត្រូវរបស់អ្នកគាំទ្រ:

ក្រោមការណែនាំ និង ការត្រួតពិនិត្យដោយផ្ទាល់ពីសំណាក់គណៈកម្មាធិការគ្រប់គ្រងគំរោង និង អង្គភាពរដ្ឋបាលមូលដ្ឋាន អភិបាលស្រុក ខណ្ឌ អ្នកគាំទ្រមានតួនាទី និង ការទទួលខុសត្រូវដូចខាងក្រោម :

ក. អ្នកគាំទ្រខេត្ត ក្រុង

- ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងគំរោង និង ដោយមានអង្គភាពរដ្ឋបាលមូលដ្ឋានជាលេខាធិការ អ្នកគាំទ្រខេត្ត ក្រុងត្រូវរៀបឯកសារសម្ភារៈទាំងអស់ទាក់ទងទៅនឹងឃុំ សង្កាត់ដូចជាៈ ទិន្នន័យឃុំ សង្កាត់ ផែនទី សកម្មភាព/កម្មវិធីរបស់ទីភ្នាក់ងារជំនាញ និង អង្គការមិនមែនរដ្ឋាភិបាលប្រសិនបើមាន... ហើយផ្តល់ឧបករណ៍ទាំងនេះអោយឃុំ សង្កាត់ តាមរយៈអ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌ សំរាប់បម្រើដល់ដំណើរការកសាងផែនការឃុំ សង្កាត់ ។

- សម្ភារៈ ឯកសារទាំងនេះត្រូវបញ្ចូលពតិមានចាំបាច់ទាំងអស់ ដែលត្រូវផ្តល់ដោយថ្នាក់ខេត្ត ក្រុង ផ្អែកទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការ អនុក្រឹត្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ប្រកាស ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អនុក្រឹត្យ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង សេចក្តីណែនាំរបស់ គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។

- ចូលរួមរៀបចំ និង សំរបសំរួលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ខណ្ឌ ។

- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌទៅតាមការចាំបាច់ ។

- ផ្អែកតាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងគំរោង និង ផ្អែកតាមការចាំបាច់ធ្វើទំនាក់ទំនងជាមួយមន្ទីរពាក់ព័ន្ធនានា ដើម្បីប្រមែប្រមូលពតិមានសម្រាប់គាំទ្រចំពោះដំណើរការកសាងផែនការ ។

- ជួយអភិបាលខេត្ត ក្រុង និង អង្គភាពរដ្ឋបាលមូលដ្ឋាន ក្នុងការត្រួតពិនិត្យនិត្យានុកូលភាពសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

- ផ្អែកតាមការណែនាំរបស់អភិបាលខេត្ត ក្រុង គណៈកម្មាធិការគ្រប់គ្រងគំរោង និងតាមការចាំបាច់ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់ ដូចជាការសិក្សាផ្នែកបច្ចេកទេស បទបញ្ជា និង នីតិវិធីដែលបានកំណត់ក្នុងការរៀបចំកសាងផែនការ ។

- សហការជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានដើម្បីរៀបចំរបាយការណ៍ស្តីពីការវិវឌ្ឍន៍នៃការអនុវត្តន៍ការងារ ។

- ជាជំនួយការជូនអភិបាលខេត្ត ក្រុង គណៈកម្មាធិការគ្រប់គ្រងគំរោង និង អង្គភាពរដ្ឋបាលមូលដ្ឋាន ក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ការប្រជុំដើម្បីពិនិត្យកែសំរួល...ការរៀបចំកសាងផែនការនៅថ្នាក់ខេត្ត ក្រុង ។

ខ. អ្នកគាំទ្រស្រុក ខណ្ឌ

- ក្រោមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងគំរោង សហការជាមួយអង្គភាពរដ្ឋបាលមូល-

ដ្ឋាន និង អភិបាលស្រុក ខណ្ឌ ធានាអោយបានថា ពតិមានទាំងអស់សំរាប់ដំណើរការកសាងផែនការឃុំ សង្កាត់ ដែលមន្ទីរនានាជុំវិញខេត្ត ក្រុង បានចងក្រង ត្រូវបានផ្តល់ឃុំ សង្កាត់សំរាប់កសាងផែនការ ។

- ពិភាក្សា និង ពិគ្រោះយោបល់ ជាមួយឃុំ សង្កាត់ រៀបចំគំរោងពេលវេលា និង អនុវត្តដំណើរការកសាងផែនការបានត្រឹមត្រូវតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

- ផ្តល់ការគាំទ្រ និងការសំរបសំរួលផ្នែកបច្ចេកទេសចាំបាច់ដល់ឃុំ សង្កាត់ក្នុងការកសាងផែនការ ។

- ជួយក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការផែនការ និង ថវិកា ក្នុងការកសាងផែនការដោយអនុលោមទៅតាមដំណាក់កាល និង ជំហានដែលបានគូសបញ្ជាក់នៅក្នុងប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

- បំពេញការងារដោយពិគ្រោះយោបល់ និង សហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ និង ស្មៀនឃុំ សង្កាត់ ។

- រាយការណ៍ជូនអភិបាលស្រុក ខណ្ឌ និង អង្គភាពរដ្ឋបាលមូលដ្ឋានពីបញ្ហា និង ការគាំទ្រដែលចាំបាច់នៅ ក្នុងដំណើរការកសាងផែនការឃុំ សង្កាត់ ហើយកែតំរូវកំហុសឆ្គងទាំងនោះទៅតាមប្រព័ន្ធច្បាប់ និង សេចក្តីណែនាំរបស់រដ្ឋាភិបាល និង គណៈកម្មាធិការគ្រប់គ្រងគំរោង ។

- ជួយឃុំ សង្កាត់អោយបង្ហាញសេចក្តីព្រាងផែនការនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ខណ្ឌហើយដាក់ បញ្ចូលសំណូមពររបស់សិក្ខាសាលាទៅក្នុងសេចក្តីព្រាងផែនការរបស់ឃុំ សង្កាត់ប្រសិនបើចាំបាច់ ។

(មានការណែនាំលំអិតក្នុងឧបសម្ព័ន្ធទី២)

VI. តួនាទី និង ការទទួលខុសត្រូវរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន :

ជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និង ជាអង្គភាពនាំមុខក្នុងការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានមានតួនាទី និង ការទទួលខុសត្រូវ ដូចខាងក្រោម :

- សំរបសំរួលជាមួយបណ្តាក្រសួង និង ខេត្ត ក្រុងសំរាប់គាំទ្រដល់ដំណើរការ កសាងផែនការ

- សម្របសម្រួលជាមួយបណ្តាក្រសួង និង មន្ទីរដែលពាក់ព័ន្ធ ឱ្យចូលរួមក្នុងការគាំទ្រចាំបាច់ ដូចជា ផ្នែកគោលនយោបាយ ផ្នែកបច្ចេកទេស

- ធានាអោយបានថាគណៈកម្មាធិការគ្រប់គ្រងគំរោងត្រូវបានបង្កើតឡើង ហើយដំណើរការបានល្អ

- ធានាអោយបានថា អ្នកគាំទ្រត្រូវបានជ្រើសរើសទៅតាមរបៀបដែលមានតម្លាភាព មានការប្រកួតប្រជែង និង មានយុត្តិធម៌ត្រឹមត្រូវ

- ទទួល និង បូកសរុបរបាយការណ៍ពីខេត្ត ក្រុង និង ពីអ្នកគាំទ្រ

• ក្នុងករណីចាំបាច់លើកសំណើជូនបណ្ដាក្រសួងពាក់ព័ន្ធ ដើម្បីប្រើប្រាស់បុគ្គលិកនៅមន្ទីរជាខ្សែបណ្ដោយនៅថ្នាក់ខេត្ត ក្រុង ដើម្បីរួមចំណែកក្នុងការគាំទ្រដល់ខេត្ត ក្រុងក្នុងកិច្ចដំណើរការអនុវត្តគំរោង

• ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល និង ទាក់ទាញឱ្យមានការចូលរួមគាំទ្រក្នុងដំណើរការ ដូចជាការគាំទ្រផ្នែកធនធាន និង បច្ចេកទេស ឬ អ្នកគាំទ្រ ក្នុងន័យនេះ ដោយស្នើទៅអភិបាលខេត្ត ក្រុងដើម្បីពង្រឹងកិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និង ស្វែងរកការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស

• ទទួលរបាយការណ៍ជាប្រចាំអំពីសកម្មភាពដែលកំពុងអនុវត្ត រួមមាន សកម្មភាពដែលមានការវិវឌ្ឍន៍ និង បញ្ហាផ្សេងៗ ហើយធ្វើការប្រឹងប្រែងដើម្បីកែតំរូវបញ្ហាទាំងនេះ

• ចាត់តាំងបុគ្គលិករបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ឱ្យចុះសហការជាមួយខេត្ត ក្រុង ដើម្បីធានាអោយមានដំណើរការអនុវត្តគំរោងនេះប្រកបដោយជោគជ័យ

• រៀបចំក្រុមពិនិត្យតាមដានដែលមានមន្ត្រីមកពីក្រសួងសំខាន់ៗ ហើយចុះពិនិត្យតាមដានអោយបានយ៉ាងតិចពីរដងនៅខេត្ត ក្រុង នីមួយ ៗ នៅក្នុងអំឡុងពេលអនុវត្តដំណើរការ

• រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអភិបាលខេត្ត ក្រុង និងជាមួយមន្ត្រីបង្គោលអង្គភាពរដ្ឋបាលមូលដ្ឋាននៅក្នុងខេត្ត ក្រុងទាំង ៧ ដើម្បីបង្កើតអោយមានការយល់ដឹងរួម ហើយណែនាំអោយខេត្ត ក្រុងត្រៀមលក្ខណៈ និង ចាត់ចែងអនុវត្តកិច្ចដំណើរការនេះឱ្យទទួលបានជោគជ័យ

• ចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ និង សិក្ខាសាលាពិនិត្យកែសំរួលនៅថ្នាក់ខេត្ត ក្រុង ដោយត្រូវរៀបចំអោយមានអ្នកផ្ដល់មតិសំខាន់ៗ ដែលនឹងបញ្ជាក់ពីគោលនយោបាយ ពិស័យនានារបស់រាជរដ្ឋាភិបាលដែលខេត្ត ក្រុង ត្រូវផ្ដោតការយកចិត្តទុកដាក់នៅក្នុងអំឡុងពេលអនុវត្ត កម្មវិធីនេះ ពីទិសដៅ និងតំរូវការផ្សេងៗដើម្បីធានាឱ្យកម្មវិធីនេះប្រព្រឹត្តទៅទទួលបានជោគជ័យ ។

• រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងបំពេញការងារនៅក្នុងខេត្ត ក្រុងទាំង ៧ ដើម្បីផ្ដល់ពត៌មានអំពីកម្មវិធីដល់អង្គការទាំងនេះ ហើយស្វែងរកលទ្ធភាពដើម្បីបង្កើតភាពជាដៃគូទាំងផ្នែកធនធាន និង បច្ចេកទេសក្នុងការគាំទ្រដល់ដំណើរការ

• ធ្វើរបាយការណ៍អំពីកម្មវិធីនៅពេលចាំបាច់ និង រៀបចំរបាយការណ៍ចុងក្រោយ ដោយគូសបញ្ជាក់ចំណុចខ្លាំង ចំណុចខ្សោយ និង បទពិសោធន៍ដែលទទួលបានពីកម្មវិធី

• ផ្សព្វផ្សាយបទពិសោធន៍តាមរយៈគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

• រៀបចំការបណ្ដុះបណ្ដាលកែលំអជំនាញសំរាប់អ្នកសំរបសំរួល

• ផ្ដល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ខេត្ត ក្រុង ផ្អែកទៅតាមថវិកាដែលបានឯកភាព និង រៀបចំការផ្ដល់ហិរញ្ញវត្ថុបន្ថែមទៀត ប្រសិនបើថវិកាមិនគ្រប់គ្រាន់

• រក្សាឯកសារហិរញ្ញវត្ថុអោយបានសមស្របបំផុត និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុដើម្បីដាក់ជូនកម្មវិធី

អភិវឌ្ឍន៍សហប្រជាជាតិ

- ផ្តល់មតិផ្នែកគោលនយោបាយ សេចក្តីណែនាំ ការគាំទ្រ ។

VII. សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត ក្រុង :

ខេត្ត ក្រុងនីមួយ ៗ ត្រូវរៀបចំសិក្ខាសាលាពិគ្រោះយោបល់រយៈពេលមួយថ្ងៃ មុនពេលអនុវត្តកម្មវិធី ។ ករណីចាំបាច់មួយចំនួនក្នុងការរៀបចំសិក្ខាសាលាពិគ្រោះយោបល់ :

- ខេត្ត ក្រុង នីមួយ ៗ នឹងកំណត់កាលបរិច្ឆេទសំរាប់សិក្ខាសាលាឱ្យបានឆាប់បំផុត
- អភិបាលខេត្ត ក្រុង ក្នុងនាមគណៈកម្មាធិការគ្រប់គ្រងគំរោងត្រូវអញ្ជើញប្រធានមន្ទីរជុំវិញខេត្ត ក្រុង អភិបាលស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និង ស្មៀនឃុំ សង្កាត់ អ្នកសំរបសំរួល អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាបាល ដើម្បីវាយតំលៃ និង រៀបចំកម្មវិធី និង ទិសដៅលំអិតក្នុងការអនុវត្តន៏
- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មន្ទីរពាក់ព័ន្ធ គណៈកម្មាធិការគ្រប់គ្រងគំរោង ត្រូវជំរាបអ្នកចូលរួមទាំងអស់ អំពីភារកិច្ចដែលត្រូវបំពេញ និង ដំណើរការដែលត្រូវអនុវត្ត
- ពិភាក្សា និង ឯកភាពទៅលើការរួមចំណែកអំពីមធ្យោបាយ សម្ភារៈ និង ធនធានមនុស្ស ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងដំណើរការកសាងផែនការ (ការគាំទ្រផ្តល់ដោយមន្ទីរនានា អ្នកសំរបសំរួល អភិបាលស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋា ភិបាល ។ល។)
- ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗនឹងយល់ច្បាស់អំពីការចាប់ផ្តើមកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងត្រូវរៀបចំបង្ហាញពីក្តីរំពឹង និង សេចក្តីត្រូវការរបស់ខ្លួននៅក្នុងការកសាងផែនការ
- អ្នកសំរបសំរួលថ្នាក់ស្រុក ខណ្ឌ នឹងត្រូវចាត់តាំងអោយបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
- ក្រុមប្រឹក្សាឃុំ សង្កាត់ និង អ្នកគាំទ្រថ្នាក់ស្រុក ខណ្ឌ ត្រូវពិភាក្សា ឯកភាពកំណត់កាលបរិច្ឆេទនៃការប្រជុំលើក ទីមួយនៅឃុំ សង្កាត់ ដើម្បីណែនាំពីដំណើរការកសាងផែនការ
- អង្គភាពរដ្ឋបាលមូលដ្ឋាន និង មន្ទីរនានានៅខេត្ត ក្រុងពិនិត្យ និង ផ្តល់យោបល់ដើម្បីឱ្យមានកិច្ចសហការ និង សំរបសំរួល
- កំណត់ពេលវេលាផ្តល់ឧបករណ៏សម្រាប់បម្រើឱ្យការកសាងផែនការឃុំ សង្កាត់ ជូនខេត្ត ក្រុង ពីអង្គភាពដែលពាក់ព័ន្ធនៅខេត្ត ក្រុង
- ការពិភាក្សា និង ឯកភាពពីការរួមចំណែកដើម្បីគាំទ្រដល់កិច្ចដំណើការ
- អង្គភាពរដ្ឋបាលមូលដ្ឋានត្រូវបូកសរុបរបាយការណ៏សិក្ខាសាលា ។

(ការរៀបចំជាក់ស្តែងមានអធិប្បាយក្នុងឧបសម្ព័ន្ធទី៣) ។

VIII. សិក្ខាសាលាពិនិត្យកែសំរួលកម្មវិធីដែលរៀបចំនៅថ្នាក់ខេត្ត ក្រុង :

ខេត្ត ក្រុងត្រូវរៀបចំសិក្ខាសាលានេះ បន្ទាប់ពីកម្មវិធីបានបញ្ចប់ ។ អ្នកចូលរួមទាំងអស់ដែលមានវត្តមាននៅក្នុងសិក្ខាសាលាពិគ្រោះ យោបល់ នឹងចូលរួមជាថ្មីម្តងទៀតនៅក្នុងសិក្ខាសាលាពិនិត្យកែសំរួល ។ ទិសដៅចំបងរបស់សិក្ខាសាលាគឺពិនិត្យ កែសំរួលការអនុវត្តន៍គំរោង និង បទពិសោធន៍ ហើយលើកសំណូមពរសំរាប់អនុវត្តនៅពេលខាងមុខ ដើម្បីកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និង ខេត្ត ក្រុង ។

ជ.គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
សមាជិកអចិន្ត្រៃយ៍

<u>ចម្លងជូន :</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងដែលជាសមាជិកគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
-ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
-គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
-កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ
-អង្គការ GTZ មូលនិធិ-ខុនរ៉ាដ-អាដិនណៅអែរ
" ដើម្បីជូនជ្រាប និង សហការ "
-អគ្គនាយករដ្ឋបាល
-ប្រតិភូរាជរដ្ឋាភិបាល និង អភិបាលខេត្ត ក្រុងទាំង ៧ " ដើម្បីអនុវត្ត "
-ឯកសារ កាលប្បវត្តិ